**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងត្រីមាសទី១នេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦៣៩ ១៣៨ហ.ត ស្មើនឹង១៣៨,២៦% នៃផែនការចំនួន ៤៦២ ២៨០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេស បទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោម កិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយ កសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាល ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍ សំខាន់ៗក្នុងត្រីមាសទី១ ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្ងាយ រួមទាំងការបន្តរៀបចំ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការ អនុវត្តផែនការប្រចាំឆ្នាំ២០២២ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុង ត្រីមាសទី១ ឆ្នាំ២០២២ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលបញ្ចប់ផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំងបញ្ចប់

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៤០ ២៣២ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១ ៦០៧ហ.ត ស្មើនឹង០,២៥% និងដោយគ្រឿងយន្តចំនួន ៦៣៨ ៦២៥ហ.ត ស្មើនឹង៩៩,៧៥%
- ផ្ទៃដីសាបសម្រេចបានចំនួន ៥ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៣៩ ១៣៨ហ.ត ស្មើនឹង១៣៨,២៦% នៃផែនការចំនួន ៤៦២ ២៨០ហ.ត តិចជាងឆ្នាំមុន ១០ ៤០១ហ.ត។

#### ១.២ ល្បឿនការងារប្រមូលផលស្រូវប្រាំងបញ្ចប់

-ការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៥៣៣ ៤០០ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ៤២៣ ៨០៦តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៥៤៤តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំងបញ្ចប់

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៥ ៥៧៦ហ.ត ស្មើនឹង៩៩,៤៩% នៃផែនការចំនួន ៣៥ ៧៦០ហ.ត តិចជាងឆ្នាំមុន ២ ៧៩៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១០៤ ៤៣១ហ.ត ស្មើនឹង១១៦,២៨% នៃផែនការចំនួន ៨៩ ៨១០ហ.ត លើសឆ្នាំមុន ៣ ៥០៤ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

## ១.៤ ការនាំចេញផលិតផលកសិកម្ម

### ១.៤.១ ការនាំចេញអង្ករ

ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ការនាំចេញអង្ករមានបរិមាណចំនួន ១៧០ ៥៣៩តោន កើនឡើងចំនួន ១៦ ៨៥១តោន (១០,៩៦%) បើធៀបនឹងបរិមាណនាំចេញក្នុងត្រីមាសទី១ ឆ្នាំ២០២១ មានចំនួន ១៥៣ ៦៨៨តោន។ ការនាំចេញអង្ករក្នុងខែមីនា ឆ្នាំ២០២២ មានចំនួន ៦៧ ៤៨១តោន ថយចុះចំនួន ៩ ៩៨៥តោន (-១២,៨៩%) បើធៀបនឹងខែមីនា ឆ្នាំ២០២១ ដែលមានចំនួន ៧៧ ៤៦៦តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ១២០ ៤២២តោន ស្មើនឹង៧០,៦១% អង្ករសគ្រប់ប្រភេទមានចំនួន ៤៨ ៨២៧តោន ស្មើនឹង២៨,៦៣% និងអង្ករចំហុយគ្រប់ប្រភេទមានចំនួន ១ ២៩០តោន ស្មើនឹង០,៧៦%។

បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២១ប្រទេស មានបរិមាណសរុបចំនួន ៤៧ ៦៧៤តោន (កើនឡើងចំនួន ១២ ២៣២តោន ស្មើនឹង៣៤,៥១%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ៨៨ ៦៤៦តោន (កើនឡើងចំនួន ៣ ២៧៦តោន ស្មើនឹង៣,៨៤%) ទិសដៅអាស៊ានចំនួន ៤ប្រទេស មានបរិមាណសរុបចំនួន ១៧ ៣១០តោន (កើនឡើងចំនួន ៥ ៦៥២តោន ស្មើនឹង៤៨,៤៨%) និងទិសដៅដទៃទៀតចំនួន ២១ប្រទេស មានបរិមាណសរុបចំនួន ១៦ ៩០៩តោន (ថយចុះចំនួន ៤ ៣០៩តោន ស្មើនឹង-២០,៣១%)។

ក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៤៦ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន១០ មានរហូតដល់ ១២៣ ៣៦៤តោន (៧២,៣៤%) និងក្រុមហ៊ុនចំនួន ៣៦ដទៃទៀតបាននាំចេញត្រឹមតែ ៤៧ ១៧៥តោន (២៧,៦៦%)។

### ១.៤.២ ការនាំចេញស្រូវ

ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ការនាំចេញស្រូវមានចំនួន ១ ៣៩០ ១៨១តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ៩០៨ ៦២៥តោន) ដែលមានការកើនឡើងចំនួន ១៦៨ ៥៣៦តោន (១៣,៨០%) បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២១ ដែលមានចំនួន ១ ២២១ ៦៤៥តោន។

### ១.៤.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ២ ៣៥៤ ៩០៦,៦៣តោន កើនឡើងចំនួន ៧៧ ៧៣៤,៧១តោន ស្មើនឹង៣,៤១% បើធៀបនឹងត្រីមាសទី១ ឆ្នាំ២០២១ មានចំនួន ២ ២៧៧ ១៧១,៩២តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ២៥២ ៣៤០តោន (កើនឡើងចំនួន ១២,៧៥%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ៩១៩ ០៥០តោន និងប្រទេសវៀតណាមចំនួន ៣៣៣ ២៩០តោន
- ដំឡូងមីស្រស់មានចំនួន ៣៥៣ ៩៥០តោន (កើនឡើងចំនួន ៤៥,៨១%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ២៩៩ ០០០តោន និងប្រទេសថៃចំនួន ៥៤ ៩៥០តោន
- ម្សៅដំឡូងមីមានចំនួន ២៥ ២៦១តោន (កើនឡើងចំនួន ៩០,១៥%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២៤ ៧៥៨តោន សហរដ្ឋអាមេរិកចំនួន ៤០៨តោន ប្រទេសណេដឺឡែនចំនួន ៧៦តោន និងប្រទេសអ៊ីតាលីចំនួន ១៩តោន
- កាកសំណល់ដំឡូងមីមានចំនួន ៦ ១២២,៨៩តោន (កើនឡើងចំនួន ១៣៩,៣២%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៥ ៦២២,៨៩ និងប្រទេសវៀតណាមចំនួន ៥០០តោន
- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ២៧១ ៩៩៤,៤៨តោន (ថយចុះចំនួន -៣៩,៦៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ២៧១ ៩៨០,៩០តោន និងប្រទេសចិនចំនួន ១៣,៥៨តោន
- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ២១៣,៤១តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១២៣,៣៨តោន ប្រទេសថៃចំនួន ៧៦តោន ប្រទេសជប៉ុន ១២,១០តោន និងកោះតៃវ៉ាន់ ១,៩៣តោន
- គ្រាប់ពោតមានចំនួន ៥៥ ៤៤៦,៩២តោន (ថយចុះចំនួន -៤៩,១២%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥៤ ៨៦០តោន កោះតៃវ៉ាន់ចំនួន ៥៧៤,៦២តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន
- គ្រាប់សណ្តែកបាយមានចំនួន ៨ ៩០០តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសវៀតណាម
- គ្រាប់សណ្តែកសៀងមានចំនួន ៥២ ០១០តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥០ ៦៦០តោន និងប្រទេសថៃចំនួន ១ ៣៥០តោន

- ផ្លែចេកស្រស់មានចំនួន ១០៣ ៦២៦,៨៤តោន (ថយចុះចំនួន -១៣,៤៦%) ក្នុងនោះនាំចេញទៅប្រទេសចិន ចំនួន ៩៨ ៥៣០,២៦តោន និងប្រទេសវៀតណាមចំនួន ៥ ០៩៦,៥៨តោន

- ផ្លែក្រូចថ្លុងមានចំនួន ៣ ៧៥០តោន (ថយចុះចំនួន -៧៦,១៤%) នាំចេញទៅប្រទេសថៃ

- ផ្លែស្វាយស្រស់មានចំនួន ៨១ ៤១៨,០៧តោន (ថយចុះចំនួន -២០,៧៣%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤០ ៨៤៩,៧២តោន ប្រទេសចិនចំនួន ២២ ២៤៤,៦៨តោន ប្រទេសថៃចំនួន ១៨ ១៨១,១២តោន និងប្រទេសកូរ៉េចំនួន ១៤២,៥៥តោន

- ដំណាប់ស្វាយមានចំនួន ៥ ១៣៦,២៧តោន (ថយចុះចំនួន -១៣,៤៣%) ក្នុងនោះនាំចេញទៅប្រទេសចិន ចំនួន ៤ ៤១៤,១១តោន ប្រទេសថៃចំនួន ២៨៨,៤៤តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសហ្វីលីពីនចំនួន ១៩២,៥៥តោន ប្រទេសជប៉ុនចំនួន ២៥តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសកូរ៉េចំនួន ៣,៨៧តោន និងប្រទេសអ៊ីតាលីចំនួន ២,៥២តោន

- ទឹកស៊ីរ៉ូស្វាយមានចំនួន ៤០៣,៤២តោន (ថយចុះចំនួន -៧៥,៦៧%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២៤៦តោន និងប្រទេសហ្វីលីពីនចំនួន ១៥៧,៤២តោន

- ដូងប្រេងមានចំនួន ១១ ៣៦០តោន (ថយចុះចំនួន -៣,៦២%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ៩ ៧០០តោន ប្រទេសម៉ាឡេស៊ីចំនួន ១ ៥០០តោន និងប្រទេសថៃចំនួន ១៦០តោន

- ម្រេចមានចំនួន ៣ ០៧២,៩៤តោន (កើនឡើងចំនួន ១៧៥,០៦%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាម ចំនួន ២ ៩៣០,០១តោន ប្រទេសអាល្លឺម៉ង់ចំនួន ១០៥,៦០តោន ប្រទេសម៉ាឡេស៊ីចំនួន ១៣,៦៤តោន ប្រទេសប៊ែលហ្ស៊ិក ចំនួន ៨,៨០តោន ប្រទេសបារាំងចំនួន ៧,៨៩តោន សាធារណរដ្ឋឆែកចំនួន ២,៣០តោន ប្រទេសកាណាដាចំនួន ១តោន ប្រទេសជប៉ុនចំនួន ១តោន សហរដ្ឋអាមេរិកចំនួន ០,៩២តោន ចក្រភពអង់គ្លេសចំនួន ០,៩០តោន ប្រទេសស៊ុយអ៊ែត ចំនួន ០,៤៩តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,២៩តោន និងប្រទេសអូស្ត្រាលីចំនួន ០,១០តោន

- ថ្នាំជក់មានចំនួន ៧៩០,៤១តោន (កើនឡើងចំនួន ១៧២,៥១%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាម ចំនួន ៧៣៥,៧០តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន និងប្រទេសហ្វីលីពីនចំនួន ១៥,១១តោន

- បន្លែចម្រុះមានចំនួន ២៤,៥១តោន (កើនឡើងចំនួន ១,៥៣%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ១៨ ០៧៥តោន (ថយចុះចំនួន -៦០,២៧%) នាំចេញទៅប្រទេសថៃ

- ម្ទេសក្រៀមមានចំនួន ១ ៤០០,១៦តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ៤០០តោន និងប្រទេសប៊ែលហ្ស៊ិកចំនួន ០,១៦តោន

- និងផលិតផលចំនួន ៤៤មុខ ផ្សេងទៀតមានចំនួន ៩៩ ៦១០,៣១តោន។

#### ១.៤.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល

ក្នុងត្រីមាសទី១ ឆ្នាំ២០២២ ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ១ ២៦៨ ៥៩៣ ៧៨០,៧៣ដុល្លារអាមេរិក ដែលក្នុងនោះ៖

- ការនាំចេញអង្ករមានចំនួន ១៤៥ ៨១០ ៨៤៥ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ២៤៨ ៨៤២ ៣៩៩ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៨៧៣ ៩៤០ ៥៣៦,៧៣ដុល្លារអាមេរិក។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូរយៈពេល២ខែសម្រេចបានចំនួន ៤៩ ០៣៣តោន កើនឡើងចំនួន ១ ៦២១តោន ស្មើនឹង៣% ធៀបរយៈពេល២ខែ ឆ្នាំ២០២១

- ផលិតផលឈើកៅស៊ូរយៈពេល២ខែសម្រេចបានចំនួន ១ ៤២៨ម$^3$។

២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់រយៈពេល២ខែសម្រេចបានចំនួន ៤៨ ៥០៩តោន កើនឡើងចំនួន ២ ៥៣៦តោន ស្មើនឹង៦% ធៀបរយៈពេល២ខែ ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូរយៈពេល២ខែសម្រេចបានចំនួន ១ ២៩៤ម៣។

២.៤ តម្លៃកៅស៊ូ

- តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងរយៈពេល២ខែ គឺ១ ៥៨៥ដុល្លារ/តោន បានថយចុះចំនួន ២ដុល្លារ/តោន ស្មើនឹង ០,១% ធៀបរយៈពេល២ខែ ឆ្នាំ២០២១

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសាររយៈពេល២ខែ គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៩០០៛/គ.ក្រ ដល់ ៦ ១៧៥៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៦០០៛/គ.ក្រ ដល់ ៣ ១៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (SENTINEL_2) ឆ្នាំ២០២២ចំនួន ៤ផ្ទាំង

- រៀបចំផែនទី PDF សម្រាប់ប្រើប្រាស់ក្នុង Avenza តាមបណ្តាផ្នែករដ្ឋបាលព្រៃឈើនីមួយៗ និងបានជូនទៅផ្នែករដ្ឋបាលព្រៃឈើចំនួន១៦

- សហការជាមួយគម្រោងវ៉េដបូកកម្ពុជា-កូរ៉េ ដោយសម្របសម្រួលលើការងារល្បាតព្រៃសហគមន៍ដល់សហគមន៍ព្រៃឈើចំនួន ១៤កន្លែង ក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៧៦គ្រឿង និងយានយន្តចំនួន ១២៥គ្រឿង ជូនក្រុមហ៊ុនចំនួន ៦និងអ្នកស្នើសុំចំនួន ២នាក់

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន៣ និងអ្នកស្នើសុំចំនួន៣នាក់ដែលមានឈើហ៊ុបមូលចំនួន ៣ ៣៣៤ម៣ កូនឈើចម្រុះចំនួន ២៥ ៦៥០ដើម អុសចម្រុះចំនួន ១០ ៤២៣ស្ទែរ ឬស្សីចំនួន ៩៣៣,៥៧០តោន និងជ័រទឹកចំនួន ១៤០តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ក្រុមការងារសិក្សាស្រាវជ្រាវ និងអង្កេតតាមដានវត្តមានសត្វព្រៃបានចុះទៅធ្វើការសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ និងដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ១៤គ្រឿង ដើម្បីថតចាប់យករូបភាពសត្វព្រៃដែលគំរាមកំហែងគ្រប់ប្រភេទ

- ចុះពិនិត្យសាកសពសត្វដំរីចំនួន ១ក្បាល ប្រវែងដងខ្លួន៣,៣ម៉ែត្រ កំពស់១,៩ម៉ែត្រ ទទឹងដងខ្លួន១,១ម៉ែត្រ ទំងន់ប្រហែលជាង១តោន ប្រភេទដំរីវ័យជំទង់ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃកែវសីមាត្រូវបានរកឃើញនៅក្នុងចម្ការដំឡូងនៅភូមិពូចារ ឃុំស្រែព្រះ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី

- ប្រមូលសំណាកសត្វចៃតឹកកែ និងចៃចេញពីសត្វស្រុក និងសត្វព្រៃស្ថិតនៅក្នុងខេត្តកោះកុងចំនួន ១០០ក្បាល

- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១៥ច្បាប់ ក្នុងនោះ៦ច្បាប់សម្រាប់ថែរក្សាសត្វក្រចៀកកាំ និង៩ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងៗដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កំពង់ធំ សៀមរាប បន្ទាយមានជ័យ ក្រចេះ កំពង់ធំ និងខេត្តបាត់ដំបង។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមចំនួន ១១៧ ៤១៣ក្បាល ក្នុងនោះកូនកើតក្នុងខែមានចំនួន ១០ ១៤៣ក្បាល

- បាននិងកំពុងថែរក្សាសត្វព្រៃចំនួន ១ ៦៧៨ក្បាល (បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ)

- សង្គ្រោះសត្វព្រៃថ្មីចំនួន ២៣៧ក្បាល និងព្យាបាលចំនួន ៩៣ក្បាល និងស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងលែងទៅព្រៃធម្មជាតិវិញចំនួន ១៩៣ក្បាល

- ក្រុមល្បាតសហគមន៍ចំនួន ២៦នាក់បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺះ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- តាមដានក្រពើប្រចាំឆ្នាំ ដោយរកឃើញលាមកក្រពើចំនួន ៦៦ដុំ ឃើញក្រពើផ្ទាល់ចំនួន ២ក្បាល និងស្លាកស្នាមដានជើងចំនួន ៤កន្លែង ព្រមទាំងលែងក្រពើភ្នំពូជសុទ្ធចំនួន ២៥ក្បាលទៅក្នុងស្ទឹងធម្មជាតិ ក្នុងភូមិពោធិ៍បឹង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង

- ជួសជុលអគារ និងទ្រុងសត្វសរុបទំហំ ១ ០០៩ម៉ែត្រការ៉េ នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយការពារចម្ការគ្រញូងសរុបប្រវែង ៥១ ៥៧៨ម៉ែត្រ ស្ថិតនៅក្នុងខេត្តកំពង់ធំ ព្រះសីហនុ ស្វាយរៀង និងខេត្តសៀមរាប

- ចុះសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត និងមន្ទីរជំនាញពាក់ព័ន្ធ ដើម្បីចុះបញ្ជីដីទំហំ ៤៧,៦៧៧ហ.ត ស្ថិតក្នុងខេត្តកំពត ដើម្បីបង្កើតជាសួនភូតគាម

- ចុះពិនិត្យទីតាំងដីសម្រាប់ត្រៀមរៀបចំពិធីរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២២ នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសំបួរមាសស្ថិតនៅភូមិសំបួរមាស ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ ៧៤៧ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ ៣៩ហ.ត ចម្ការឈើដាំទំហំ ៥៨៤ហ.ត និងចម្ការរុក្ខទិវា ៩កក្កដាទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បណ្តុះកូនឈើចំនួន ៨៤ ១៣០ដើម ក្នុងនោះថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៣៣ ៤០០ដើម និងថ្នាលបណ្តុះកូនឈើចំនួន ៦មានចំនួន ៥០ ៧៣០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើចំនួន ១៤២ករណី (ព្រៃឈើចំនួន ៨០ករណី សត្វព្រៃចំនួន ១៩ករណី និងកាប់រានដីព្រៃចំនួន ៤៣ករណី)

- វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន ៥ ៥៨៦ម៣ ឈើអារចំនួន ២៧២ម៣ សត្វព្រៃចម្រុះប្រភេទចំនួន ១ ២៨៤ក្បាល និង៣៨៧គ.ក្រ ផ្ទៃដីព្រៃឈើដែលកាប់រានទំហំ ២២៦ហ.ត

- វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ១១០ករណី ធ្វើកិច្ចសន្យាចំនួន ២១ករណី និងដកហូតចំនួន ២៦ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១កន្លែងស្ថិតក្នុងខេត្តកំពត និងពន្យារសុពលភាពចំនួន ៨កន្លែងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ស្វាយរៀង បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តព្រៃវែង

- ពិនិត្យសំណើសុំពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៤កន្លែងស្ថិតនៅខេត្តត្បូងឃ្មុំ កំពង់ធំ សៀមរាប និងខេត្តព្រះសីហនុ ព្រមទាំងសិក្សាអត្រាកែច្នៃកូនឈើទំហំគល់ ១៥-៣០ស.ម ចំនួន១ក្រុមហ៊ុន

- ក្រុមហ៊ុនចំនួន ៦នាំចេញផលិតផលរានទេរ៉ាត និងឈើអារកែច្នៃទៅក្រៅប្រទេសចំនួន ២៧៣ម៣ ជ័រទឹកចំនួន ៥៨តោន និងធ្យូងអាកាស្យាចំនួន ៤២តោន

- ក្រុមហ៊ុនចំនួន ១នាំចូលឈើកែច្នៃចំនួន ២៨០ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ៥មានបរិមាណឈើកែច្នៃចំនួន ៨០ម៣ គ្រឿងសង្ហារឹមឬស្សីកែច្នៃចំនួន ២២តោន និងជ័រទឹកចំនួន ៣៧តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ២មានបរិមាណឈើកែច្នៃចំនួន ៥១២ម៣

- ពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ១មានបរិមាណឈើកែច្នៃចំនួន ២៨ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ១ ១៨៩ ៣២២ ១៦៤រៀល និង១៧៩ ០១២,១៣ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជា

លក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្ដល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបចំនួន ៥០ករណី ក្នុងនោះ មិនមានលិខិតអនុញ្ញាតត្រឹមត្រូវ ១២ករណី (បទល្មើស)។ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៦១ ៧៨២លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះប្រជុំផ្សព្វផ្សាយស្ដីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្ដាខេត្តចំនួន៤។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្ដីព្រាងប្រកាសអន្តរក្រសួងស្ដីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្ដីព្រាងប្រកាសស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្ដុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១១៥ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ៧ ៥៤០វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្ដាសាយបក្សី និងជំងឺប៉េស្ដជ្រូកអាហ្វ្រិក (ASF)។ វត្ថុវិភាគចំនួន ២វិជ្ជមានជំងឺដុំពកស្បែកគោក្របី (LSD) មានប្រភពមកពីភូមិក្រដាស ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីសម្រេចបានចំនួន ៦៥០តោន ស្មើនឹង៦,៥០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន
- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ៤០ ០០០តោន ស្មើនឹង១៣,៣៣% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៣៧ ៣០០តោន
- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៩ ៣០០តោន ស្មើនឹង៦,៦៤% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៣ ៥០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ២៦ ១០០តោន ស្មើនឹង២០,០៨% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ កើនឡើងចំនួន ៣០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ១០ ២៦០តោន ស្មើនឹង២,៨៥% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៦៦ ៧៤០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២៥ ៨០០ក្បាល ស្មើនឹង៨,៦០% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ១ ៧០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៤៧ ៥០០ ០០០កូន ស្មើនឹង១៥,៨៣% នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ២ ០០០ ០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ១៣ ៦០០តោន ស្មើនឹង១៧% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ១ ៦១០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ២ ៧៣០តោន ស្មើនឹង២២,៧៥% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ កើនឡើងចំនួន ៣០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ១១ ៥០០ ០០០លីត្រ ស្មើនឹង២៣% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៧៥០ ០០០លីត្រ។

**៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល**

- សំណុំរឿងបទល្មើសជលផលមានចំនួន ៣៩៦ករណី ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ២៥២ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៣៧៩ករណី និងសមុទ្រចំនួន ១៧ករណី។

**៥.៥ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់នាំចេញចំនួន ៤១៥តោន ស្មើនឹង៥,១៩% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ៥៦៣តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ១៣១តោន។

**៥.៦ ការប្រមូលថវិកា**

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១៧០ ៦៨៧ ៨៧៥រៀល ស្មើនឹង៤៧,៥២% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២១ ថយចុះចំនួន ១៦៦ ៩៦៨ ៩០៤រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចូលរួមអមដំណើរគណៈប្រតិភូគណៈកម្មការទី៣នៃរដ្ឋសភា ចុះបេសកកម្មដើម្បីស្វែងយល់អំពីសមិទ្ធផលការរីកចម្រើន និងបញ្ហាប្រឈមនានារបស់ខេត្តកំពង់ស្ពឺ

- ទទួលពាក្យបណ្តឹងចំនួន ២ករណី

- ចុះស្រាវជ្រាវពាក្យបណ្តឹងពាក់ព័ន្ធនឹងការងារដឹកនាំ និងគ្រប់គ្រងរបស់ការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ

- ចុះស្រាវជ្រាវពាក្យបណ្តឹងរបស់ឈ្មោះ អ៊ុំ វុទ្ធី ប្តឹងពាក់ព័ន្ធនឹងការងារដឹកនាំ និងគ្រប់គ្រងរបស់ខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ២១១ករណី លើវិស័យព្រៃឈើ៥៨ករណី ជលផល៥៩ករណី សុខភាពសត្វនិងផលិតកម្មសត្វ២៣ករណី កៅស៊ូ២ករណី ក្សេត្រសាស្ត្រ២ករណី នីតិកម្ម១ករណី និងវិស័យផ្សេងៗ៦៦ករណី

- ចូលរួមប្រជុំទូទៅចំនួន ១៩លើក និងចូលរួមពិធីផ្សេងៗ២លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ២ ២០០ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៩១១ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៨៩២ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៣៩៧ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ២ ៦០២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ២៣៤ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៧៣ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំត្រីមាសទី១

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំ

ដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំកិច្ចប្រជុំអន្តរក្រសួង និងផ្ទៃក្នុងចំនួន ៤១លើក មានអ្នកចូលរួមសរុបចំនួន ៥៨៤នាក់
- រៀបចំពិធីចុះហត្ថលេខាចំនួន ១លើក មានអ្នកចូលរួមសរុបចំនួន ៦០នាក់
- ទទួលភ្ញៀវអន្តរជាតិចំនួន ១២លើក មានអ្នកចូលរួមសរុបចំនួន ១២៥នាក់
- រៀបចំពិធីសន្និបាតក្រសួង (មានអ្នកចូលរួមពិធីបើកចំនួន ១៧១នាក់ និងពិធីបិទចំនួន ១៦៦នាក់)
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩១៨នាក់ (ស្រី១ ៤៦៣នាក់ ស្មើនឹង២៤,៧២%) រួមមាន៖
    + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩៧៣នាក់ (ស្រី៨៥៤នាក់ ស្មើនឹង២៩,០២%)
    + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៤៥នាក់ (ស្រី៦០៩នាក់ ស្មើនឹង២០,៧០%)
- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៣០នាក់ (ស្រី៧នាក់)
- រៀបចំប្រកាសស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ២២នាក់ (ស្រី៥នាក់) ទៅក្រៅក្រសួងចំនួន៦នាក់
- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌដោយមរណភាពចំនួន ៩នាក់
- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកសរុបចំនួន ១៨នាក់ (ស្រី១១នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៩នាក់ (ស្រី១នាក់) សម្រាកលំហែមាតុភាពចំនួន ៧នាក់ សម្រាកព្យាបាលជំងឺចំនួន ១នាក់ និងច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ១នាក់
- រៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១៦នាក់
- រៀបចំប្រកាសស្តីពីការអនុញ្ញាតឱ្យចូលបម្រើការងារវិញបន្ទាប់ពីដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៦នាក់
- រៀបចំលិខិតស្តីពីសំណើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ២០២២ ជូនមន្ត្រីរាជការនៃក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១ ៩៧៥នាក់
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៨១១នាក់ (ស្រី២១៣នាក់) ក្នុងនោះ៖
    + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៧៨១នាក់ (ស្រី២០៧នាក់)
    + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ៣០នាក់ (ស្រី៦នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- ចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣
- រៀបចំសំណើសុំផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទី២០២២-២០២៧
- រៀបចំសំណើសុំធាតុចូលសម្រាប់រៀបចំលក្ខន្តិកៈយោងសម្រាប់គម្រោង Spatial Tools និងសេវាកម្ម អាកាសធាតុ
- រៀបចំសំណើសុំផ្តល់ព័ត៌មានពាក់ព័ន្ធនឹងបទដ្ឋានអនាម័យភូតគាមអនាម័យ និងដំណើរការរដ្ឋបាលសម្រាប់ការនាំចូលផ្លែស្រកានាគមកកម្ពុជា
- រៀបចំសំណើសុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០
- ចុះធ្វើការណែនាំ និងធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២២ នៅខេត្តក្រចេះ កំពង់ឆ្នាំង តាកែវ និងខេត្តបាត់ដំបង ដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្ត និងស្រុក
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥
- ចុះពិនិត្យ និងតាមដានការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅខេត្តបាត់ដំបង ប៉ៃលិន ព្រះវិហារ និងខេត្តឧត្តរមានជ័យ

- ចុះតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពក្នុងក្របខ័ណ្ឌថវិកាកម្មវិធីចំនួន ៤ខេត្ត រួមមាន៖ ខេត្តរតនគិរី ព្រះវិហារ កំពង់ចាម និងខេត្តកោះកុង។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន៦ ៣៧០ លានរៀលស្មើនឹង១៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ២២ ៨៣៨លានរៀល ស្មើនឹង១៥% ធៀបនឹង ច្បាប់ថវិកាឆ្នាំ២០២២

- រៀបចំសំណើសុំថវិកាចំនួន ៣ ៩១៧ ៨០០ ០០០រៀល ដើម្បីទូទាត់ដំណាក់កាលទី២ ជូននាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មសម្រាប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្មចំនួន៨នៅក្នុងខេត្តកំពង់ស្ពឺ កណ្តាល កំពង់ចាម ត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ១៨ក្រុមហ៊ុន

- រៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន ២៦ក្រុមហ៊ុន

- សហការរៀបចំ និងចូលរួមជាមួយគណៈកម្មការអន្តរក្រសួង (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ចុះពិនិត្យ និងវាយតម្លៃលើការងារអនុវត្តកិច្ចសន្យាស្តីពីការងារហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមសហគមន៍កសិកម្មចំនួន៨នៅក្នុងខេត្តគោលដៅចំនួន ៥រួមមាន៖ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម និងខេត្តត្បូងឃ្មុំក្នុងឆ្នាំ២០២១ ដែលអនុវត្តដោយនាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម

- ចុះពិនិត្យ និងផ្ទៀងផ្ទាត់តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០២១ របស់រដ្ឋបាលជលផល នាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានកសិ-ឧស្សាហកម្ម វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ និងខេត្តកំពង់ចាម។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២១ និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស

- ចុះធ្វើសវនកម្មចំនួន ៩សវនដ្ឋាន ស្មើនឹង២៣,០៧% នៃផែនការ៣៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន២៦អនុសាសន៍
និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥០,៧៩% នៃផែនការចំនួន៥៦%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ទទួលជួបពិភាក្សាការងារជាមួយស្ថានទូត៥លើក អង្គការអន្តរជាតិ១លើក និងវិស័យឯកជន១លើក

- ចូលរួមកិច្ចប្រជុំចំនួន ១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគីលើការងារក្រៅប្រទេស

- ចូលរួមសិក្ខាសាលាចំនួន ១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងសិក្ខាសាលា៣លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស

- សម្របសម្រួលរៀបចំរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-នូវែលសេឡង់ ដើម្បីត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ក្រសួងការបរទេសកម្ពុជា-នូវែលសេឡង់លើកទី២

- សម្របសម្រួលដើម្បីកំណត់យកតារាងនិយ័តកម្មថវិកានៃគម្រោងការកសាងសមត្ថភាពរបស់សមាជិកនៃប្រទេសតាមដងទន្លេមេគង្គ ដើម្បីការពារសត្វផ្សោតទឹកសាប និងជីវចម្រុះ

- រៀបចំកិច្ចអន្តរាគមន៍បញ្ជូនឯកសារទស្សនទានស្តីពីការកែលម្អពូជគោនៅកម្ពុជាទៅកាន់ស្ថានទូតប្រេស៊ីលនៅទីក្រុងបាងកក

- សម្របសម្រួលរៀបចំការចុះហត្ថលេខារវាងអង្គការ FAO ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ១លើក

- សម្របសម្រួលលិខិតករណីសំណើផ្តល់ធាតុចូលលើវិស័យអាទិភាពដែលស្នើឡើងដោយកម្ពុជាសម្រាប់ផែនការការងារនៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបីឆ្នាំ២០២៣-២០២៧

- សម្របសម្រួលលិខិតសំណើសុំគោលការណ៍អនុញ្ញាតបែងចែកអង្ករបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូកបីដែលផ្តល់ដោយប្រទេសកូរ៉េ ដល់ប្រជាពលរដ្ឋក្រីក្ររងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ចំនួន៧ ៥០០គ្រួសារ។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៨ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៨ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៧ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ២៥ក្រុមហ៊ុន សរុបចំនួន ១២៨សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- រៀបចំសិក្ខាសាលាស្តីពីគោលការណ៍សម្រាប់ស្លាកសញ្ញាព័ត៌មាន និងគំរូស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្មនៅខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់
- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈចំនួន ៣ខេត្ត គឺខេត្តកំពង់ធំ ព្រះវិហារ និងខេត្តកំពង់ចាម។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៩ក្រុមហ៊ុន
- ចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ៨រាជធានី-ខេត្ត គឺរាជធានីភ្នំពេញ ខេត្តកណ្តាល ព្រៃវែង បន្ទាយមានជ័យ បាត់ដំបង ស្ទឹងត្រែង ព្រះវិហារ និងខេត្តរតនគិរី ដោយត្រួតពិនិត្យលើដេប៉ូ១០ដេប៉ូ និង២០ក្រុមហ៊ុន ពុំមានពិន័យអន្តរការណ៍ទេ។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ដកស្រង់ព័ត៌មានកសិកម្មប្រចាំថ្ងៃចេញពីបណ្តាញផ្សព្វផ្សាយសារព័ត៌មានសរុបចំនួន ៤១៣ព័ត៌មាន
- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ចុះតាមដាន និងពង្រឹងការប្រើប្រាស់គេហទំព័ររបស់មន្ទីរ និងប្រមូលធាតុចូលសម្រាប់បង្កើតកម្មវិធីទូរស័ព្ទនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ៤ រួមមានៈ ខេត្តកំពង់ស្ពឺ តាកែវ កោះកុង និងខេត្តកែប
- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១
- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តលើគេហទំព័រសរុបចំនួនផុស ១ ១៨២ព័ត៌មាន
- ចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដើម្បីរៀបចំជាផែនទីដំណាំកសិកម្មស្ថិតនៅក្នុងភូមិសាស្ត្រចំនួន២ គឺឃុំត្រពាំងឫស្សី និងឃុំកំពង់ស្វាយមានដំណាំសំខាន់ៗ រួមមានៈ ដំណាំស្រូវ ស្វាយ ស្វាយចន្ទី កៅស៊ូ អាកាស្យា ខ្នុរ អំពៅ ព្រីង និងដំណាំស្រែការនាគ
- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋាន-កិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ១០៦ក្បាល/ច្បាប់
- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកដែលមានអ្នកចូលអានចំនួន ២៣ ៣៧៣ដង/នាក់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះទៅថត Video បទយកការណ៍ចំនួន ៣ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញវេទិកាស្វែងយល់អំពីកសិកម្មចំនួន ១ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញនាទីចុះស្រែជាមួយកសិករចំនួន ៥ប្រធានបទ

- ធ្វើការចាក់ផ្សាយអត្ថបទបច្ចេកទេសកសិកម្មជាសម្លេងនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ១៨ប្រធានបទ
- ចងក្រង និងបោះពុម្ពផ្សាយទស្សនាវដ្តីសមិទ្ធផលកសិកម្មប្រចាំឆ្នាំ២០២១ ចំនួន ១ ៣០០ច្បាប់
- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ១១សំណួរ-ចម្លើយ លើប្រធានបទបច្ចេកទេសចិញ្ចឹមមាន់ គោ ពពែ ត្រី ជំងឺលើដំណាំក្រូចឆ្មា និងដំណាំផ្សិត មកពីខេត្តកំពង់ធំ ស្វាយរៀង សៀមរាប ព្រៃវែង កណ្តាល និងខេត្តកំពង់ចាម។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ៩៤កិច្ចសន្យា រួមមាន៖ ខេត្តពោធិ៍សាត់៥កិច្ចសន្យា ស្ទឹងត្រែង៧កិច្ចសន្យា តាកែវ១កិច្ចសន្យា មណ្ឌលគិរី១កិច្ចសន្យា កំពង់ស្ពឺ២៨កិច្ចសន្យា កែប៤កិច្ចសន្យា កណ្តាល៣កិច្ចសន្យា ព្រះវិហារ១កិច្ចសន្យា ត្បូងឃ្មុំ១កិច្ចសន្យា សៀមរាប១១កិច្ចសន្យា កំពង់ចាម៤កិច្ចសន្យា ស្វាយរៀង១៣កិច្ចសន្យា និងខេត្តបន្ទាយមានជ័យ ១៥កិច្ចសន្យា
- ចុះសម្របសម្រួលបណ្តុះបណ្តាលបុគ្គលិកអំពីប្រព័ន្ធសុវត្ថិភាពចំណីអាហារ (HACCP) និងចុះពិនិត្យការអនុវត្ត និងគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពក្នុងការកែច្នៃគ្រាប់ស្វាយចន្ទីនៅខេត្តកំពង់ធំ
- ចុះសិក្សាសក្តានុពលផ្គត់ផ្គង់គ្រឿងសមុទ្រនៅខេត្តព្រះសីហនុ
- ចុះប្រមូលទិន្នន័យ និងធាតុចូលសម្រាប់ការរៀបចំគោលការណ៍ណែនាំពាក់ព័ន្ធនឹងអាហារូបត្ថម្ភនៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ
- ចុះសិក្សារៀបចំអភិវឌ្ឍន៍ស្តង់ដារគ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ចាម និងខេត្តកំពង់ធំ
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅនឹងទីផ្សារតាមរយៈផលិតកម្មកសិកម្ម តាមកិច្ចសន្យានៅខេត្តកំពង់ឆ្នាំង
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តសៀមរាប
- ចុះបណ្តុះបណ្តាលស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តកំពត
- ចុះបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មនៅខេត្តរតនគិរី
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសក្រោយប្រមូលផលនៃផលិតកម្មកសិកម្មនៅខេត្តបាត់ដំបង
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាម កិច្ចសន្យានៅខេត្តព្រៃវែង
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការស្រាវជ្រាវ និងពង្រឹងភាគីដែលបាននឹងកំពុងអនុវត្តកិច្ចសន្យាផលិតកម្ម កសិកម្មនៅខេត្តកំពង់ស្ពឺ
- ចុះបណ្តុះបណ្តាលស្តីពីការជំរុញកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកម្ពស់ការយល់ដឹងពីទីផ្សារអេឡិចត្រូនិក ដល់ជនជាតិភាគតិចក្នុងខេត្តរតនគិរី
- ប្រមូលទិន្នន័យ និងធាតុចូលសម្រាប់ការរៀបចំគោលការណ៍ណែនាំពាក់ព័ន្ធនឹងអាហាររូបត្ថម្ភនៅខេត្តក្រចេះ និងខេត្តមណ្ឌលគិរី
- ចុះសិក្សាគុណភាពគ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ធំ កំពង់ចាម ព្រះវិហារ និងខេត្តរតនគិរី
- បញ្ចូលទិន្នន័យ និងវាយតម្លៃលើផលិតផលចំនួន ៥០០ប្រភេទ ដែលទទួលបានពីការស្ទង់មតិពី៥រាជធានី-ខេត្ត រួមមាន៖ ខេត្តសៀមរាប ព្រៃវែង កំពត ស្ទឹងត្រែង និងរាជធានីភ្នំពេញ
- បាននិងកំពុងពិភាក្សាពិគ្រោះយោបល់ និងរៀបចំពិធីការជាមួយអ្នកជំនាញការបច្ចេកទេស MRLs ដើម្បីអនុវត្ត ការសិក្សាស្រាវជ្រាវការកាត់បន្ថយកម្រិតកាកសំណល់ថ្នាំកសិកម្មក្នុងការដាំដុះប្រភេទជីនាងវងដោយប្រើប្រាស់ថ្នាំពុលកសិកម្ម ក្លរភីរីហ្វូស និងសាយភីមេហ្ស៊ីន។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានបានចំនួន ៣៩ប្រភេទ រួមមាន៖ ស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៨ប្រភេទ សរុបចំនួន ២ ៥១៧បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៩ ២៩៣បញ្ជីក/សំណាក
- ធ្វើពិសោធន៍ចំនួន ២៧ប្រភេទ នៅ៨០កន្លែង ព្រមទាំងបានធ្វើការអង្កេតស្រាវជ្រាវចំនួន ៣លើក

- រៀបចំបើកវគ្គបណ្តុះបណ្តាលកសិករចំនួន ៤លើក មានកសិករចូលរួមចំនួន ១៥៦នាក់ (ស្រី១១៣នាក់ ស្មើនឹង ៧២,៤៤%) និងធ្វើទិវាស្រែបង្ហាញចំនួន ១លើក មានកសិករចូលរួមចំនួន ៣៩នាក់ (ស្រី១៤នាក់ ស្មើនឹង៣៥,៨៩%)

- ក្នុងត្រីមាសទី១ ឆ្នាំ២០២២ នេះ មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ១៧៧ ០៤០នាក់ ដោយគិតជាមធ្យមមានប្រមាណ២ ២១៣នាក់/ថ្ងៃ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- ដឹកនាំនិស្សិតឆ្នាំទី២ និងឆ្នាំទី៣នៃមហាវិទ្យាល័យកសិឧស្សាហកម្ម និងមហាវិទ្យាល័យវិស្វកម្មកសិកម្មចំនួន ៧០នាក់ ចុះទស្សនកិច្ចសិក្សានៅកសិដ្ឋានគោទឹកដោះគិរីស្ហួគ៌ ខេត្តតាកែវ

- រៀបចំសិក្ខាសាលាស្តីពីការវាយតម្លៃគម្រោងប្លង់មេរៀនកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋានការកែលម្អគោលការណ៍សរសេរសារណាបទ ព្រមទាំងការរៀបចំធ្វើគោលការណ៍ធ្វើតេស្តស្តង់ដារ និងការផ្តួចផ្តើមបង្កើតកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត គាំទ្រដោយគម្រោង HEIP

- ចុះវាយតម្លៃ និងវាស់វែងគុណភាពហ្គាសរបស់ប្រព័ន្ធចម្រោះជីវឧស្ម័ននៅកសិដ្ឋាន M's Pig I & II ដែលមានទីតាំងនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងកសិដ្ឋានចិញ្ចឹមជ្រូកចំនួន ២កន្លែងទៀត នៅខេត្តកំពង់ស្ពឺ ដើម្បីពិនិត្យមើលដំណើរការប្រព័ន្ធជីវឧស្ម័ន

- រៀបចំវេទិកាផ្សព្វផ្សាយចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានស្តីពី ឱកាសនៃការផ្លាស់ប្តូរការសិក្សានៅវិទ្យាស្ថាន Oniris ប្រទេសបារាំងរយៈពេលខ្លី (៦ខែ) ក្រោមកិច្ចសហការរវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថាន Oniris ប្រទេសបារាំង ដោយសាស្ត្រាចារ្យបណ្ឌិត Lionel Boillereaux

- សហការជាមួយសាកលវិទ្យាល័យហ្វីលីពីន ឡូសបាណូស (UPLB) រៀបចំសិក្ខាសាលាស្តីពីការសរសេរសៀវភៅគោលការណ៍ណែនាំធានាគុណភាពអប់រំរបស់សាលាក្រោយឧត្តម

- ចូលរួមធ្វើបទបង្ហាញអំពីលទ្ធផលនៃការស្រាវជ្រាវពាក់ព័ន្ធជីវឧស្ម័នក្នុងសន្និសីទអន្តរជាតិស្តីពីការកែលម្អបរិស្ថាន និងអភិវឌ្ឍន៍ជនបទលើកទី13 (ICERD)

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចម្រាញ់យកសារធាតុ សេរីស៊ីន (Sericin) ចេញពីសម្បុកស្ទូត្រ សម្រាប់ផលិតធ្វើគ្រឿងសំអាង។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ៣៦២នាក់ (ស្រី៣៧៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើៈ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្តៅ អាហារ ថ្នាំសត្វល្អិត និងជី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន

- ចុះតាមខេត្តដើម្បីពិនិត្យទីតាំងសិក្សាស្រាវជ្រាវចំនួន ១៥លើក។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៥៩៤នាក់ (ស្រី២០៩នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ផលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូនកូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍ក្លូន (ទិន្នផលជ័រ) សរុបចំនួន ១២ចម្ការពិសោធន៍

- ត្រួតពិនិត្យការប្តូរមុខចៀរ និងផ្ទាំងចៀរចម្ការពិសោធន៍នៅក្នុងស្ថានីយចំនួន ១១ចម្ការ

- ត្រួតពិនិត្យចម្ការបង្ហាញនៅខេត្តមណ្ឌលគិរីស្តីពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រដោយមានការសហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងអង្គការ WWF-កម្ពុជា

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នាដើម្បីលាបរំញោចតាមពិធីសាពិសោធន៍

- រៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (Latex diagnosis-LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose) Suc) និង Thiol (R-SH)

- ថែទាំកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០២១-២០២២

- អនុវត្តការបំប៉ៅកូនកៅស៊ូនៅថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០២១-២០២២

- ត្រួតពិនិត្យការប្រមូលផលទឹកជ័រ និងបញ្ចូលទិន្នន័យគ្រប់ចម្ការពិសោធន៍

- អនុវត្តការងារមន្ទីរពិសោធន៍តាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017

- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) ចំនួន ៨សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដារ CSR

- ចូលរួមធ្វើតេស្តប្រៀបធៀបអន្តរមន្ទីរពិសោធន៍ក្នុងក្របខណ្ឌសមាគមន៍កៅស៊ូអន្តរជាតិ (Round Robin Crosscheck) ជាមួយ International Rubber Association (IRA) លើកទី១២៦។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៦៣៩ ១៣៨ហ.ត ស្មើនឹង១៣៨,២៦% នៃផែនការចំនួន ៤៦២ ២៨០ហ.ត ការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ៥៣៣ ៤០០ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ៤២៣ ៨០៦តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៥៤៤តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តរៀបចំផែនការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ
- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) នឹងជំងឺឆ្លងសត្វផ្សេងៗ
- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត
- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់
- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ
- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋាន

ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែចេត្រ ឆ្នាំខាល ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**